# ម្តាយ និងកូនស្រីទាំងឡាយ

*អែលឌើរ អិម រ័សុល បាឡឺដ*
*នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់*

កាលពីប្រាំមួយខែកន្លងមុន ខ្ញុំបានថ្លែងសុន្ទរកថានៅក្នុងសម័យប្រជុំបព្វជិតភាពទូទៅទៅកាន់ឪពុក និងកូនប្រុសទាំងឡាយ។ ដូចដែលអ្នកបានដឹងថា ខ្ញុំមានកូនស្រីប្រាំនាក់ និងចៅស្រីម្ភៃបួននាក់ ហើយចំនួនចៅស្រីតួតកាន់តែកើនឡើងយ៉ាងច្រើន នោះបានត្រូវសុំឱ្យចំណាប់អារម្មណ៍លើខ្លួនស្មើរគ្នា។ ដូច្នេះ នៅថ្ងៃនេះ ខ្ញុំនឹងនិយាយជាពិសេសទៅកាន់ម្តាយ និងកូនស្រីទាំងឡាយដែលត្រូវបានសុំឱ្យមានចំណាប់អារម្មណ៍លើខ្លួនស្មើរគ្នា។ នៅថ្ងៃនេះ ខ្ញុំនឹងនិយាយជាពិសេសចំពោះម្តាយ និងកូនស្រីទាំងឡាយនៅក្នុងសាសនាចក្រ។

ភរិយាជាទីស្រឡាញ់របស់ខ្ញុំ បាបារ៉ា មានឥទ្ធិពលយ៉ាងសំខាន់ដ៏នៅអស់កល្បជានិច្ចចំពោះកូនស្រី និងចៅស្រីរបស់យើង ហើយពួកគេក៏មានឥទ្ធិពលចំពោះភរិយារបស់ខ្ញុំដែរ។ ម្តាយ និងកូនស្រីទាំងឡាយដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការជួយគ្នាទៅវិញទៅមកស្វែងរកលទ្ធភាពដ៏នៅ អស់កល្បជានិច្ចរបស់ពួកគេ ទោះបីជាមានឥទ្ធិពលនៃលោកិយធ្វើឱ្យភាពជាស្ត្រី និងម្តាយ កំពុងតែត្រូវបានរងនូវការហិចហោច និងពុករលួយក្តី។

ប្រធានយ៉ូសែប អេហ្វ ស៊្មីធ បាននិយាយទៅកាន់ស្ត្រីនៃសាសនាចក្រជិតមួយសតវត្សរ៍ថា៖ «អ្នកពុំត្រូវបណ្តោយទុកឱ្យត្រូវបានដឹកនាំដោយស្ត្រីនៅក្នុងពិភពលោកទេ ប៉ុន្តែអ្នកត្រូវ... ដឹកនាំស្ត្រីនៅក្នុងពិភពលោកវិញ ចំពោះអ្វីៗដែលគួរឱ្យចង់សរសើរ អ្វីៗដែលដូចជាព្រះ អ្វីៗដែលលើកដំកើង និង... អ្វីៗដែលបរិសុទ្ធចំពោះកូនរបស់មនុស្ស» (Relief Society General Board Minutes ឆ្នាំ 1914)។

បងប្អូនស្ត្រីទាំងឡាយ យើងទាំងអស់គ្នាដែលជាបងប្អូនប្រុសរបស់អ្នក ពុំអាចធ្វើអ្វីដែលអ្នកត្រូវបានរៀបចំដោយទេវភាពពីមុនកំណើតផែនដីនោះទេ។ យើងអាចព្យាយាម ប៉ុន្តែយើងមិនអាចចម្លងអំណោយទានដ៏ពិសេសរបស់អ្នកបានឡើយ។ គ្មានអ្វីនៅក្នុងពិភពលោកនេះដែលមានលក្ខណៈផ្ទាល់ខ្លួន ជាលក្ខណៈអប់រំ ជាលក្ខណៈផ្លាស់ប្តូរពេញមួយជីវិតដូចជាឥទ្ធិពលរបស់ស្ត្រីដែលសុចរិតបាននោះឡើយ។

ខ្ញុំយល់ថា អ្នកដែលជាយុវនារីមួយចំនួនពុំមានម្តាយដែលអ្នកអាចពិភាក្សាអំពីបញ្ហាទាំងនេះបានឡើយ។ ហើយថាម្តាយជាច្រើនដែលពុំមានកូនស្រីនៅក្នុងជីវិតរបស់អ្នកឥឡូវនេះទេ។ ប៉ុន្តែពីព្រោះ *អ្វីៗទាំងអស់* ដែលស្ត្រីមាននៅក្នុងនិស្ស័យដ៏ទេវភាពរបស់នាង ទាំងទេពកោសល្យដែលមាន និងទំនួលខុសត្រូវចំពោះម្តាយ ភាគច្រើនអ្វីដែលខ្ញុំនិយាយនឹងអនុវត្តស្មើគ្នាថ្នាំពោះជីដូន មីង បងប្អូនស្រី ម្តាយចុង ម្តាយក្មេង អ្នកដឹកនាំ និងចំពោះអ្នកធ្វើការប្រៀនប្រដៅទាំងឡាយ ដែលនៅពេលខ្លះធ្វើកិច្ចការប្រហាក់ប្រហែលគ្នា

ចំពោះ ទំនាក់ទំនងដ៏សំខាន់នៃម្ដាយ-កូនស្រីទាំងនេះ។

យុវនារីទាំងឡាយ ម្ដាយរបស់អ្នកស្រឡាញ់អ្នកណាស់។ ពួកគាត់មើលឃើញអ្នកនៅក្នុងជំនាន់អនាគតដែលបានសន្យា។ អ្វីៗដែលអ្នកបានសំរេច ឧបសគ្គដែលអ្នកបានយកឈ្នះ នាំឱ្យពួកគាត់មានសេចក្ដីស្រឡាញ់ដ៏បរិសុទ្ធ។ ហើយដូចគ្នានេះផងដែរ សេចក្ដីព្រួយបារម្ភ និងការឈឺចាប់ *របស់អ្នក* គឺជាសេចក្ដីព្រួយបារម្ភ និងការឈឺចាប់ *របស់ពួកគាត់។*

នៅថ្ងៃនេះ ខ្ញុំសូមផ្ដល់នូវមតិមួយចំនួនអំពីរបៀបដែលអ្នកអាចទាញយកអត្ថប្រយោជន៍ទាំងមូល ពីទំនាក់ទំនងរបស់អ្នកជាមួយនឹងម្ដាយរបស់អ្នក។ ហើយបន្ទាប់មក ខ្ញុំមានគំនិតមួយចំនួនដើម្បីចែកចាយជាមួយនឹងម្ដាយ អំពីរបៀបដែលពួកគាត់អាចពង្រឹកឥទ្ធិពលរបស់ពួកគាត់ចំពោះកូនស្រីរបស់ពួកគាត់ ក៏ដូចជាសមាជិកនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់។

វាជារឿងល្អណាស់ ដែលមនុស្សទាំងអស់ងាយស្រួលបង្ហាញអំពីការភាន់ច្រឡំ និងការផ្លាស់ប្ដូរនៃភាពជាស្ត្រីនៅក្នុងសង្គមសព្វថ្ងៃ។ ស្ត្រីដែលគ្មានភាពសមរម្យ គ្មានសីលធម៌ អត្តសញ្ញាណរបស់ស្ត្រីផ្សព្វផ្សាយពាសពេញរលកអាកាស គ្រប់ទស្សនាវដ្ដី ហើយមាននៅលើកញ្ចក់ខ្សែភាពយន្ត---ដែលជាអ្វីៗត្រូវបានប្រារព្ធឡើងដោយខាងលោកិយ។ សាវកប៉ុល និយាយព្យាករអំពី "ពេលវេលាដ៏មានគ្រោះថ្នាក់" ដែលនឹងកើតឡើងនៅក្នុងថ្ងៃចុងក្រោយ ហើយជាពិសេសសំអាងទៅលើអ្វីដែលអាចមើលទៅហាក់ដូចជា មានគ្រោះថ្នាក់យ៉ាងខ្លាំងចំពោះគាត់: «ស្ត្រីទាំងនោះផ្ទុកធ្ងន់ ដោយអំពើបាបហើយ ក៏បណ្ដោយតាម សេចក្ដីប៉ង់ប្រាថ្នាផ្សេងៗ» (ធីម៉ូថេទី 2 3:6)។ វប្បធម៌ដ៏ពេញនិយមនៅសព្វថ្ងៃនេះ ជាញឹកញាប់ធ្វើឱ្យស្ត្រីមើលទៅឆ្កួតលីលា មិនសមហេតុសមផល មិនគិតគូរ និងគ្មានអំណាច។ វាគ្មានគោលដៅ ហើយគ្មានការគោរពចំពោះពួកគេ និងបន្ទាប់មកផ្ដល់យោបល់ថា ពួកគេអាចមានបន្សល់ទុកនូវកិត្តិនាមរបស់ពួកគេបានតែតាមរយៈខ្សែភាពយន្តប៉ុណ្ណោះ---ជាសារលិខិតដែលងាយសាយភាយគ្រោះថ្នាក់បំផុតដែលបានបញ្ជូនដល់ស្ត្រីអំពីខ្លួនរបស់ពួកគេ។

ហេតុដូច្នេះហើយ យុវនារីជាទីស្រឡាញ់របស់ខ្ញុំ ខ្ញុំសូមជំរុញទឹកចិត្តដល់អ្នកអស់ពីដួងចិត្តរបស់ខ្ញុំ ថាកុំឱ្យអ្នកមើលទៅលើវប្បធម៌សព្វថ្ងៃនេះទុកជាគំរូនៃតួនាទី និងជាអ្នកណែនាំឡើយ។ សូមសម្លឹងទៅម្ដាយដ៏ស្មោះត្រង់របស់អ្នកទុកជាគំរូដើម្បីធ្វើតាម។ ធ្វើខ្លួនអ្នកឱ្យដូចជា *ពួកគាត់* កុំឱ្យដូចជាអ្នកល្បីល្បាញដែលបទដ្ឋានរបស់ពួកគេពុំមែនជាបទដ្ឋានរបស់ព្រះអម្ចាស់ឡើយ ហើយតម្លៃរបស់ពួកគេមិនអាចមានឥទ្ធិពលដល់ទស្សនវិស័យដ៏នៅអស់កល្បជានិច្ចឡើយ។ សូមធ្វើតាមគំរូរបស់ម្ដាយអ្នក។ សូមរៀនតាមកម្លាំងសេចក្ដីក្លាហាន និងសេចក្ដីស្មោះត្រង់របស់គាត់។ ម្ដាយរបស់អ្នកប្រហែលជាពុំមែនជាអ្នកជំនាញខាងសរសេរសារទូរស័ព្ទ ម្ដាយរបស់អ្នកប្រហែលជាមិនមានឈ្មោះនៅលើកម្មវិធី Facebook (ហ្វេសប៊ុក) ។ ប៉ុន្តែនៅពេលដែលមានអ្វីកើតឡើងដែលទាក់ទងនឹងដួងចិត្ត និងកិច្ចការរបស់ព្រះអម្ចាស់ ម្ដាយរបស់អ្នកមានចំណេះវិជ្ជាយ៉ាងសន្ធឹកសន្ធាប់។ នៅពេលដែលអ្នកដល់ពេលជិតនឹងរៀបអាពាហ៍ពិពាហ៍ ហើយជា

ម្ដាយដ៏ក្មេងខ្ចី នោះម្ដាយរបស់អ្នកនឹងក្លាយជាធនធានដ៏មានប្រាជ្ញាឈ្លាសវៃ។ គ្មានមនុស្សណានៅលើផែនដី ដែលស្រឡាញ់អ្នកស្មើនឹងម្ដាយរបស់អ្នកទេ ឬមានឆន្ទៈដើម្បីពលិកម្មច្រើនក្នុងការលើកទឹកចិត្តអ្នក និង ជួយអ្នកស្វែងរកសុភមង្គល---នៅក្នុងជីវិតនេះ និងជារៀងរហូតឡើយ។

សូមស្រឡាញ់ម្ដាយរបស់អ្នក ប្អូនស្រីៗទាំងឡាយ។ សូមគោរពដល់ម្ដាយរបស់អ្នក។ សូមស្ដាប់ដល់ម្ដាយ របស់អ្នក។ សូមទុកចិត្តដល់ម្ដាយរបស់អ្នក។ ម្ដាយរបស់អ្នកគិតល្អពីអ្នកបំផុតនៅក្នុងចិត្ត។ ម្ដាយរបស់អ្នក ខ្វល់ខ្វាយអំពីសុវត្ថិភាពដ៏នៅអស់កល្បជានិច្ច និងសុភមង្គលដ៏នៅអស់កល្បជានិច្ចរបស់អ្នក។ ដូច្នេះ សូម មានចិត្តល្អចំពោះគាត់។ សូមមានចិត្តអត់ធ្មត់ជាមួយនឹងភាពមិនឥតខ្ចោះដែលម្ដាយរបស់អ្នកមាន។ យើង ទាំងអស់គ្នាពុំមានភាពឥតខ្ចោះឡើយ។

ឥឡូវនេះ ខ្ញុំសូមចែកចាយនូវគំនិតមួយចំនួនជាមួយនឹងម្ដាយទាំងឡាយ អំពីតួនាទីដ៏ពិសេស ដែលអ្នក មាន នៅក្នុងជីវិតកូនស្រី របស់អ្នក។ យើងមានគ្រួសារ និងមិត្តភក្តិ ដែលធ្វើដំណើរជាញឹកញាប់ជាមួយនឹង សមាជិកគ្រួសារ របស់ពួកគេដទៃទៀត។ ការសង្កេតឃើញរបស់នាង បន្ទាប់ពីការធ្វើដំណើរនិមួយៗ គឺថា តើយុវនារីទាំងនោះ បានមានឥរិយាបថដូចម្ដាយរបស់ពួកគេយ៉ាងណា។ ប្រសិនបើម្ដាយចេះច្នៃប្រឌិត កូន ស្រីរបស់ពួកគេក៏ចេះច្នៃប្រឌិតដែរ។ ប្រសិនបើម្ដាយមានភាពរមទម្យ កូនស្រីរបស់ពួកគេក៏ដូច្នោះដែរ។ ប្រសិនបើម្ដាយរបស់ពួកគេពាក់អាវដៃមួយ និងសំលៀកបំពាក់សាមញ្ញទៅចូលរួមការប្រជុំសាក្រាម៉ង់ កូនស្រីរបស់ពួកគេដ៏ដូច្នោះដែរ។ ម្ដាយទាំងឡាយ គំរូរបស់អ្នកគឺសំខាន់ខ្លាំងណាស់ចំពោះកូនស្រីរបស់ អ្នក---ទោះបីជាពួកគេពុំដឹងក្តី។

នៅក្នុងប្រវត្តិសាស្ត្រទាំងមូលនៃពិភពលោក ស្ត្រីតែងតែដើរតួនាទីជាគ្រូបង្រៀនខាងតម្លៃសីលធម៌។ សេចក្តីណែនាំនោះចាប់ផ្ដើមឡើងតាំងពីកូននៅក្នុងអង្រឹង បន្តរហូតដល់ពេញមួយជីវិតនៃកូនរបស់ពួក គេ។ នៅសព្វថ្ងៃនេះ សង្គមរបស់យើងគឺត្រូវបានរីកស្គុះស្គាយជាមួយនឹងសារលិខិតអំពីភាពជាស្ត្រី និង ភាពជាម្ដាយដែលមានគ្រោះថ្នាក់ និងទុច្ចរិតបំផុត។ ការធ្វើតាមសារលិខិតនេះអាចបណ្ដាលឱ្យកូនស្រី របស់អ្នក ឈានទៅរកអំពើបាប និងបំផ្លិចបំផ្លាញដល់ខ្លួន។ កូនស្រីរបស់អ្នកប្រហែលជាមិនយល់ការណ៍ នេះឡើយ លើកលែងតែអ្នកប្រាប់ដល់ពួកគេ---ឬប្រសើរជាង លើកលែងតែអ្នកបង្ហាញដល់ពួកគេ អំពី របៀបធ្វើការជ្រើសរើសដ៏ត្រឹមត្រូវ។ ក្នុងនាមជាម្ដាយនៅក្នុងអ៊ីស្រាអែល អ្នកត្រូវដាក់កូនស្រីរបស់អ្នកនៅ ជួរទីមួយប្រឆាំងនឹងឧបាយកលនៃពិភពលោក។

ឥឡូវនេះ ម្ដាយទាំងឡាយ ខ្ញុំយល់ថា នៅពេលខ្លះវាបង្ហាញថា កូនចៅរបស់យើងពុំយកចិត្តទុកដាក់ទៅ លើមេរៀន ដែលយើងកំពុងព្យាយាមបង្រៀនពួកគេនោះឡើយ។ សូមជឿលើខ្ញុំចុះ ខ្ញុំបានឃើញនូវ ចំណាប់អារម្មណ៍ដែលកើតមាន នៅក្នុងកែវភ្នែករបស់ក្មេងវ័យជំទង់ គឺនៅពេលដែលអ្នកចាប់ផ្ដើមនិយាយ អ្វីដែលជាផ្នែកដ៏សំខាន់បំផុត នៅក្នុងការបង្រៀនរបស់អ្នក។ ខ្ញុំសូមបញ្ជាក់ដល់អ្នកថា ទោះបីជានៅពេល ដែលអ្នកគិតថា កូនស្រីរបស់អ្នកមិនស្ដាប់ដល់អ្វីដែលអ្នកនិយាយ នោះគឺមានន័យថា កូនស្រីរបស់អ្នក

នៅតែកំពុងរៀនសូត្រអំពីអ្នក នៅពេលដែលនាងកំពុងតែមើលថាតើសកម្មភាពរបស់អ្នកស្របនឹងពាក្យសំដីរបស់អ្នកដែរឬទេ។ នៅពេល រ៉ហ្វេ វ៉លដូ អេមើសិន និយាយថា «ហេតុអ្វីម៉ាក់និយាយឮម្ល៉េះ កូនមិនអាចស្ដាប់ម៉ាក់បានទេ» (អ៊ិនធើរណែត ការដកស្រង់ #2323 មកពី Laura Moncur′s Motivational Quotations)។

សូមបង្រៀនកូនស្រីរបស់អ្នកឱ្យស្វែងរកសេចក្ដីរីករាយនៅក្នុងការចិញ្ចឹមកូនចៅ។ ការចិញ្ចឹមនេះហើយដែល សេចក្ដីស្រឡាញ់ និងទេពកោសល្យទាំងឡាយអាចមានសារៈសំខាន់ដ៏មហិមា ជាងគេបំផុតដ៏នៅអស់កល្បជានិច្ច។ សូមធ្វើការពិចារណានៅក្នុងបរិបទនេះអំពីពាក្យទូន្មានរបស់ប្រធាន ហារ៉ូល ប៊ី លី ថា «ការងារ...ដ៏មានសារៈសំខាន់ បំផុតដែលអ្នកមិនដែលធ្លាប់ធ្វើពីមុនមកគឺជាកិច្ចការដែលមាននៅលើជញ្ជាំងផ្ទះរបស់អ្នក» (Harold B. Lee, Decisions of Successful Living ទំព័រ 248--249)។ ពិតប្រាកដណាស់ កិច្ចការនេះគឺជាការពិតចំពោះយើងទាំងអស់គ្នា ប៉ុន្តែកិច្ចការមានអំណាចជាពិសេស នៅពេលដែលធ្វើការពិចារណាពីទំនាក់ទំនងរបស់ម្ដាយ និងកូនស្រីនោះ។

ម្ដាយទាំងឡាយសូមបង្រៀនកូនស្រីរបស់អ្នកថា បុត្រីដ៏ស្មោះត្រង់របស់ព្រះគឺត្រូវជៀសវាងនូវការល្បួងឱ្យនិយាយដើម ឬវិនិច្ឆ័យគ្នា។ នៅក្នុងទេសនកថាទៅកាន់សមាគមសង្គ្រោះនៅណៅវូ ព្យាការីយ៉ូសែប ស៊្មីធ បានប្រឹក្សាដល់បងប្អូនស្រ្តីថា «អណ្ដាតគ្មានអ្នកណាអាចផ្សាំងបានឡើយ---ទប់អណ្ដាត កុំនិយាយរឿងឥតប្រយោជន៍» (ថ្ងៃទី 26 ខែ ឧសភា ឆ្នាំ 1842)។

កាលពីប៉ុន្មានឆ្នាំមុន មានអត្ថបទមួយចំនួន ដូចជាសៀវភៅ ខ្សែភាពយន្តបានសរសេរអំពីស្ត្រី និងក្មេងស្រីដែលចូលចិត្ត និយាយដើមគេ និងអ្នកដែលមាន «ចិត្តអាក្រក់»។ សាតាំងតែងតែល្បួងបំផ្លាញនូវសារធាតុដ៏មានតម្លៃបំផុត នៃនិស្ស័យដ៏ទេវភាពរបស់ស្ត្រី---និស្ស័យក្នុងការចិញ្ចឹមបីបាច់។

ទំនាក់ទំនងម្ដាយ/កូនស្រីគឺជាកន្លែងដែលកូនស្រីម្នាក់អាចរៀនអំពីរបៀបចិញ្ចឹមបីបាច់ល្អ ដោយបានទទួលការចិញ្ចឹមបីបាច់ល្អ។ កូនស្រីត្រូវបានស្រឡាញ់។ កូនស្រីត្រូវបានបង្រៀន និងមានបទពិសោធន៍ដំបូងបំផុត ថាតើអារម្មណ៍ដែលមាននរណាម្នាក់ខ្វល់ខ្វាយចំពោះខ្លួនបែបណាដែលគ្រប់គ្រាន់ល្មម កែប្រែនាងខណៈដែលកំពុងបន្តដើម្បីលើកទឹកចិត្ត និងជឿទៅលើនាងក្នុងពេលដូចគ្នានោះ។

បងប្អូនស្ត្រីសូមចងចាំថាព្រះ គឺជាប្រភពនៃអំណាចខាងសីលធម៌ និងខាងវិញ្ញាណទាំងអស់។ យើងទទួលបានអំណាចនោះ តាមរយៈការចុះក្នុងសេចក្ដីសញ្ញាទាំងឡាយជាមួយទ្រង់ និងរក្សាសេចក្ដីសញ្ញាទាំងនោះ។ ម្ដាយទាំងឡាយ សូមបង្រៀនកូនស្រីរបស់អ្នកនូវសារៈសំខាន់នៃការធ្វើសេចក្ដីសញ្ញាទាំងឡាយហើយបន្ទាប់មកបង្ហាញអំពីរបៀបដើម្បីរក្សាសេចក្ដីសញ្ញាទាំងនោះ តាមរបៀបដែលនឹងធ្វើឱ្យមានចិត្តចង់រស់នៅ ឱ្យមានភាពសក្ដិសមដើម្បីទៅព្រះវិហារបរិសុទ្ធ។

ពិភពលោកសព្វថ្ងៃនេះ នេះមានន័យថាត្រូវនិយាយជាមួយកូនស្រីរបស់អ្នកអំពីបញ្ហាផ្លូវភេទ។ កូនស្រីរបស់អ្នក ក៏ដូចជា កូនប្រុសរបស់អ្នកផងដែរ គឺកំពុងតែធំឡើងនៅក្នុងពិភពលោក ដែលកំពុងអោបក្រសោប

យកយ៉ាងទូលំទូលាយ នូវភាពច្របូកច្របល់ដោយខ្វះការគិតពិចារណា។ ស្ត្រីដែលគ្មានភាពថ្លៃថ្នូរ និងមិនបរិសុទ្ធគឺត្រូវបានគេលើកដំកើង ហើយជាញឹកញាប់មនុស្សទាំងអស់បានកោតសរសើរ និងចង់ធ្វើតាម។ ខណៈដែលមានជំហានមួយចំនួនដែលយើងអាច អនុវត្តនៅក្នុងផ្ទះ និងក្នុងក្រុមគ្រួសាររបស់យើងគឺដើម្បីកាត់បន្ថយការរុករករបស់យើង ចំពោះសារធាតុដែលគ្មានតម្លៃ នៃជីវិតបច្ចុប្បន្នទាំងនេះ នោះកូនស្រីរបស់អ្នកមិនអាចជៀសវាងបានទាំងស្រុងនូវសារលិខិតខាងផ្លូវភេទដោយគ្មានការ លាក់លៀម ហើយទាក់ទាញដែលនៅជុំវិញពួកគេនោះឡើយ។ អ្នកត្រូវមានការពិភាក្សាជាញឹកញាប់ និងដោយបើកចំហរ នៅអំឡុងពេលដែលអ្នកបង្រៀនកូនស្រីរបស់អ្នកនូវសេចក្តីពិតអំពីបញ្ហានេះ។

ឧទាហរណ៍ ពួកគេត្រូវយល់ដឹងថា នៅពេលដែលពួកគេពាក់សំលៀកបំពាក់តឹងពេក ខ្លីពេក ឬវាលពេក នោះពួកគេមិនត្រឹមតែបញ្ជូននូវសារលិខិតខុសចំពោះយុវជនដែលពួកគេមានទំនាក់ទំនងជាមួយប៉ុណ្ណោះទេ ប៉ុន្តែពួកគេក៏ធ្វើឱ្យចងចាំនៅក្នុងគំនិតរបស់ពួកគេផ្ទាល់នូវជំនឿខុសថាតម្លៃរបស់ស្ត្រីគឺពឹងផ្អែកទៅលើរូបភាពទាក់ទាញសំបកក្រៅ។ គំនិតនេះពុំធ្លាប់មាន ឬក៏នឹងមិនដែលមាននៅក្នុងអត្ថន័យសុចរិតនៃបុត្រីដ៏ស្មោះត្រង់របស់ព្រះនោះឡើយ។ ពួកគេត្រូវតែបានស្តាប់ឮពាក្យពេចន៍នេះ---យ៉ាងច្បាស់ ហើយម្តងហើយម្តងទៀត---ចេញពីបបូរមាត់របស់អ្នក ហើយពួកគេត្រូវការមើលឃើញតាមរយៈគំរូរបស់អ្នក និងការប្រកាន់ខ្ជាប់នូវបទដ្ឋានផ្ទាល់ខ្លួនរបស់អ្នកនៅក្នុងការ ស្លៀកពាក់ ការតុបតែងខ្លួន និងការរស់នៅដោយថ្លៃថ្នូរ។

យុវវ័យទាំងអស់នឹងកាន់តែចុះ និងប្រកាន់ខ្ជាប់នូវសេចក្តីសញ្ញាទាំងឡាយ ប្រសិនបើពួកគេរៀនអំពីរបៀបដើម្បីស្គាល់នូវវត្តមាន និងសម្លេងរបស់ព្រះវិញ្ញាណបរិសុទ្ធ។ សូមបង្រៀនកូនស្រីរបស់អ្នកអំពីកិច្ចការរបស់ព្រះអម្ចាស់។ សូមឱ្យពួកគេអានព្រះគម្ពីរ។ សូមផ្តល់ឱ្យពួកគេនូវបទពិសោធន៍ទាំងឡាយដែលនឹងជួយពួកគេលើកស្ទួយនូវអំណាច បព្វជិតភាពនៅក្នុងជីវិតរបស់ពួកគេ។ តាមរយៈការចុះសេចក្តីសញ្ញាទាំងឡាយ នោះពួកគេនឹងរៀនដើម្បីស្តាប់សម្លេងនៃព្រះអម្ចាស់ ហើយទទួលវិវរណៈផ្ទាល់ខ្លួន។ ព្រះនឹងស្តាប់ឮ និងឆ្លើយចំពោះការអធិស្ឋានរបស់ពួកគេ។ បាវចនារបស់ម៉្ញូចលសំរាប់ឆ្នាំ 2010 អនុវត្តចំពោះយុវវ័យក៏ដូចជាចំពោះយើងផងដែរ៖ «ចូរឱ្យមានកម្លាំង និងចិត្តក្លាហានចុះ កុំឱ្យខ្លាចឡើយ ក៏កុំឱ្យស្រយុតចិត្តផង ត្បិតព្រះយេហូវ៉ាជាព្រះនៃឯងទ្រង់គង់ជាមួយនៅគន្លែងណាដែលឯងទៅផង» (យ៉ូស្វេ 1:9)។ កិច្ចការនេះនឹងដឹកនាំពួកគេទៅរកសុវត្ថិភាពនៃពរជ័យទាំងឡាយនៃព្រះវិហារបរិសុទ្ធ។

សូមប្រាកដថា ពួកគេបានដឹងថា ការប្រកាន់ខ្ជាប់នូវសេចក្តីសញ្ញាទាំងឡាយគឺជាផ្លូវដែលមានសុវត្ថិភាពបំផុតចំពោះសុភមង្គលដ៏នៅអស់កល្បជានិច្ច។ ហើយប្រសិនបើចាំបាច់ សូមបង្រៀនពួកគេអំពីរបៀបប្រែចិត្ត និងរបៀបបន្តមានភាពបរិសុទ្ធ និងភាពសក្តិសម។

ឥឡូវនេះ បងប្អូនប្រុសស្រីរបស់ខ្ញុំអើយ ប្រសិនបើការណ៍នេះធ្លាប់បានឮដល់អ្នក ពីព្រោះតែខ្ញុំធ្លាប់បាននិយាយទៅកាន់ ឪពុកម្តាយ និងកូនចៅរបស់ពួកគេសំរាប់សន្និសីទទូទៅបីដងជាប់ៗគ្នា។ កាលពីខែ

មេសា ឆ្នាំមុន ខ្ញុំបានលើកទឹកចិត្ត ដល់ក្រុមយុវវ័យឱ្យ «រៀនពីមេរៀនកាលពីអតីតកាល»។ ចេញពីសុន្ទរកថានេះខ្ញុំសូមដកស្រង់៖ «នៅពេលដែលអ្នកមាន ឆន្ទៈស្ដាប់ និងរៀន ការបង្រៀនដ៏សំខាន់បំផុតមួយចំនួនអំពីជីវិតកើតឡើងចេញពីអ្នកទាំងឡាយណាដែល បានធ្លាប់ឆ្លងកាត់ពីមុនអ្នក...។ តើជីវិតរបស់អ្នកនឹងបានប្រសើរយ៉ាងណាទៅ ប្រសិនបើអ្នកធ្វើតាមគំរូដ៏អស្ចារ្យពីពួកអ្នកធ្វើតាមព្រះគ្រីស្ទយ៉ាងស្មោះត្រង់»។

កាលពីសន្និសីទខែ តុលា ឆ្នាំមុន ខ្ញុំបាននិយាយទៅកាន់ឪពុក និងកូនប្រុសទាំងឡាយនៅក្នុងការប្រជុំបព្វជិតភាព ហើយនៅថ្ងៃនេះ ភាគច្រើនខ្ញុំនិយាយទៅកាន់ម្ដាយ និងកូនស្រីទាំងឡាយ។ នៅក្នុងករណីនីមួយៗសារលិខិតរបស់ខ្ញុំ គឺកើតឡើងខុសៗគ្នា ប៉ុន្ដែប្រហាក់ប្រហែលគ្នា។ ខ្ញុំសង្ឃឹមថា អ្នកកំពុងស្ដាប់ ហើយមើលឃើញនូវគំរូមួយ និងស្ដាប់ឮ និងធ្វើតាមសារលិខិតដ៏ខ្ជាប់ខ្ជួនថា នៅសម័យចុងក្រោយនេះគឺវាមានការចាំបាច់ណាស់---ថែមទាំងសំខាន់---ថាឪពុកម្ដាយ និងកូនចៅទាំងឡាយសូមស្ដាប់ ហើយរៀនពីគ្នាទៅវិញទៅមក។ ទាំងនេះពុំមែនគ្រាន់តែជាគំនិតស្រមើស្រមៃអំពីអ្វី ដែលខ្ញុំកំពុងនិយាយនោះទេ។ គំនិតទាំងនេះគឺមានខ្លឹមសារ ចំនុចសំខាន់នៅក្នុងផែនការរបស់ព្រះចំពោះសុភមង្គល និងសេចក្ដីសុខសាន្តដ៏នៅអស់កល្បជានិច្ចរបស់យើង។

សាសនាចក្រនជួយអ្វីតាមដែលអាចធ្វើបាន។ យើងនៅទីនោះដើម្បីគាំទ្រ និងលើកស្ទួយអ្នកក្នុងនាមជាឪពុកម្ដាយ និងនៅក្នុងនាមជាកូនចៅ។ ប៉ុន្ដែគេហដ្ឋាន គឺជាកន្លែងដែលមានសារៈសំខាន់បំផុត ដើម្បីរៀបចំយុវវ័យនៅសព្វថ្ងៃនេះ ដើម្បី ដឹកនាំក្រុមគ្រួសារ និងអនាគតរបស់សាសនាចក្រ។ កិច្ចការនេះបានធ្លាក់មកលើយើងម្នាក់ៗ ក្នុងនាមជាម្ដាយ និងជាឪពុក ដើម្បីធ្វើអ្វីៗដែលយើងអាចធ្វើបានដើម្បីរៀបចំយុវវ័យស្រ្ដីស្មោះត្រង់ ជាបុរស និងស្រ្ដីសុចរិត។ គឺនៅក្នុងផ្ទះនេះហើយដែលយើងត្រូវបង្រៀនដំណឹងល្អ តាមរយៈសិក្ខាបទ និងតាមរយៈគំរូ។

ខ្ញុំសូមបញ្ចប់ពាក្យទូន្មានរបស់ខ្ញុំព្រមជាមួយនឹងសេចក្ដីសង្ខេបអំពីការព្យាករណ៍របស់ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ ថា៖ «ទំនាក់ទំនង [ក្រុមគ្រួសារ] របស់យើងគឺពុំមែនមានគោលបំណងតែសំរាប់ជីវិតនេះ សំរាប់ពេលនេះទាំងស្រុង ដូចជាយើងគិតពេលនេះពីជីវិតដ៏នៅអស់កល្បជានិច្ចនោះទេ។ យើងរស់នៅសំរាប់ពេលនេះ និងសំរាប់ភាពដ៏នៅអស់កល្បជានិច្ច។ យើងបង្កើតការចូលរួមចំណែក និងទំនាក់ទំនងសំរាប់ពេលនេះ និងសំរាប់ពេល ដ៏នៅអស់កល្បជានិច្ច...។ តើមាននរណាផ្សេងទៀតក្រៅពីពួកបរិសុទ្ធថ្ងៃចុងក្រោយដែលគិតពិចារណាអំពីគំនិតហួសពីសេចក្ដីស្លាប់នេះថា យើងនឹងបន្ដស្ថិតនៅក្នុងអង្គការក្រុមគ្រួសារ? ការស្គាល់ឪពុក ម្ដាយ កូនចៅទៅវិញទៅមក... អង្គការក្រុមគ្រួសារនេះចាប់ផ្ដើមឡើងនូវអង្គភាពមួយនៅក្នុងអង្គការដ៏អស្ចារ្យ និងឥតខ្ចោះ នៃកិច្ចការរបស់ព្រះ ហើយអ្វីៗទាំងអស់គឺត្រូវបានរៀបចំឡើងដើម្បីបន្ដនៅពេលនេះ និងពេលដ៏នៅអស់កល្បជានិច្ច?» (Joseph F. Smith, Gospel Doctrine: Selections from the Sermons and Writings of Joseph F. Smith  ចងក្រងដោយ John A. Widtsoe ទំព័រ 277)។

សូមឱ្យព្រះប្រទានពរជ័យដល់យើងដើម្បីបង្រៀន ចិញ្ចឹមបីបាច់ និងរៀបចំគ្នាទៅវិញទៅមកនៅក្នុងផ្ទះរបស់យើង ចំពោះកិច្ចការដ៏មហិមាដែលយើងត្រូវតែធ្វើ តាមរយៈយើងទាំងអស់គ្នាសំរាប់ពេលនេះ និងនៅក្នុងអនាគត គឺជាការអធិស្ឋានរបស់ខ្ញុំ នៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ អាម៉ែន។